*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

# សុន្ទរកថា
# របស់ អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
# ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# ថ្លែងក្នុង
# ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ អគារការិយាល័យកណ្តាលថ្មី
# របស់ធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម (ARDB)

**រាជធានីភ្នំពេញ, ថ្ងៃអង្គារ ៧ រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧**

**ត្រូវនឹងថ្ងៃទី ៣០ ខែ មេសា គ.ស. ២០២៤**

*****+*****

- ឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ;
- ឯកឧត្តម **នេត្រ ភក្ត្រា** រដ្ឋមន្ត្រី ក្រសួងក្រសួងព័ត៌មាន;
- ឯកឧត្តម **ហួត ហាក់** រដ្ឋមន្ត្រី ក្រសួងអធិការកិច្ច;
- លោកជំទាវ **សោម គឹមសួគ៌** អគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ;
- ឯកឧត្តម, លោកជំទាវ, តំណាងក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល;
- ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, តំណាងដៃគូអភិវឌ្ឍន៍, តំណាងវិស័យឯកជន, ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ, ជាទីមេត្រី!

ថ្ងៃនេះ, ខ្ញុំពិតជាមានសេចក្តីសោមនស្សយ៉ាងក្រៃលែង ដោយបានមកចូលរួមជាអធិបតី ក្នុង **ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ អគារការិយាល័យកណ្តាលថ្មី របស់ធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម (ARDB)** ។ ខ្ញុំសូមសម្តែងនូវការស្វាគមន៍

យ៉ាងកក់ក្តៅ ចំពោះ ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, ថ្នាក់ដឹកនាំ, តំណាងក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល, តំណាងដៃគូអភិវឌ្ឍន៍, តំណាងវិស័យឯកជន, ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ, ដែលបានឆ្លៀតពេលដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងពិធី នាព្រឹកនេះ ។

ក្នុងឱកាសដ៏មហោឡារឹកនេះ, ខ្ញុំសូមសម្តែងនូវសេចក្តីសាទរ ចំពោះថ្នាក់ដឹកនាំ, មន្ត្រី និង បុគ្គលិក នៃធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម ចំពោះការទទួលបាននូវអគារការិយាល័យថ្មីដ៏ធំស្កឹមស្កៃ ដែលត្រូវបានបំពាក់ដោយប្រព័ន្ធសុវត្ថិភាពទាន់សម័យ និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទំនើប ស្របតាមបទដ្ឋានបច្ចេកទេស ដើម្បីលើកកម្ពស់គុណភាព និង ប្រសិទ្ធភាពនៃការផ្តល់សេវាជូនអតិថិជន ឱ្យកាន់តែប្រសើរ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។ ខ្ញុំក៏សូមយកឱកាសនេះ កោតសរសើរ និង វាយតម្លៃខ្ពស់ ចំពោះក្រុមប្រឹក្សាភិបាល, ថ្នាក់ដឹកនាំ, មន្ត្រី និង បុគ្គលិកទាំងអស់នៃធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម ដែលបានខិតខំអស់ពីកម្លាំងកាយ-ចិត្ត និង ប្រាជ្ញា-ស្មារតី ក្នុងការបំពេញតួនាទី និង ភារកិច្ចរបស់ខ្លួន នាពេលកន្លងទៅ, ប្រកបដោយវិជ្ជាជីវៈ និង ការទទួលខុសត្រូវ, រហូតសម្រេចបាននូវសមិទ្ធផលជាច្រើនគួរជាទីមោទនៈ, ចាប់តាំងពីស្ថាប័ននេះត្រូវបានបង្កើតឡើង មកដល់បច្ចុប្បន្ន, ជាពិសេស សម្រេចបាននូវ **អគារការិយាល័យកណ្តាលថ្មីដ៏ទំនើប** ដែលត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នាពេលនេះ ។

## ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!

ក្នុងរយៈពេល ២៦ ឆ្នាំ ចុងក្រោយនេះ, ក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាពពេញផ្ទៃប្រទេស ដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន, អតីតនាយករដ្ឋមន្ត្រី,** និង **បច្ចុប្បន្ន ជាប្រធានព្រឹទ្ធសភា,** បាននាំមកជូនប្រទេសជាតិ និង ប្រជាជនយើង តាមរយៈ **នយោបាយឈ្នះ-ឈ្នះ**, កម្ពុជាបន្តសម្រេចបាននូវសមិទ្ធផលដ៏ធំជាច្រើន ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង បានផ្លាស់ប្តូរមុខមាត់គួរជាទីមោទនៈ តាមរយៈការអនុវត្ត ប្រកបដោយជោគជ័យ នូវ **យុទ្ធសាស្ត្រត្រីកោណ, និង យុទ្ធសាស្ត្រចតុកោណទាំងបួនដំណាក់កាល,** ព្រមទាំងគោលនយោបាយ និង ផែនការយុទ្ធសាស្ត្រពាក់ព័ន្ធផ្សេងទៀត ។ ការដាក់ចេញនូវគោលនយោបាយត្រឹមត្រូវ, ចំទិសដៅ, និង ទាន់ពេល, បានជំរុញឱ្យកម្ពុជា សម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងអត្រា ប្រមាណ ៧% ជា

មធ្យម ក្នុងមួយឆ្នាំ ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ មុនការមកដល់នៃជំងឺកូវីដ-១៩, រហូតបានប្រែក្លាយកម្ពុជា ពីប្រទេសចំណូលទាប ទៅជាប្រទេសចំណូលមធ្យមកម្រិតទាប កាលពីឆ្នាំ ២០១៥ ។ លើសពីនេះទៀត, ជាមួយនឹងមូលដ្ឋានសង្គម-សេដ្ឋកិច្ចដ៏រឹងមាំ ប្រកបដោយចីរភាព, បរិយាបន្ន, សមធម៌, និង ធន់នឹងវិបត្តិ, សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថា អាចសម្រេចបានកំណើន ក្នុងរង្វង់ប្រមាណ ៥% ក្នុងឆ្នាំ ២០២៣ និង ត្រូវបានព្យាករណ៍ថា នឹងបន្តកើនឡើង ក្នុងរង្វង់ប្រមាណ ៦% នៅឆ្នាំ ២០២៤ បន្ទាប់ពីទទួលរងនូវការបង្អាក់ ដោយវិបត្តិជាសកលនៃជំងឺកូវីដ-១៩ និង ទោះបីជាកម្ពុជា ត្រូវបន្តជួបប្រឈមនឹងសភាពការណ៍សកល ដែលមានភាពមិនប្រាកដ-ប្រជាខ្ពស់ក៏ដោយ ក្នុងនោះ រួមមាន ៖ ភាពតានតឹងនៃស្ថានភាពភូមិសាស្ត្រនយោបាយ, ពិសេស សង្គ្រាមរវាងរុស្ស៊ី និង អ៊ុយក្រែន, ការប្រយុទ្ធរវាងអ៊ីស្រាអែល និង ក្រុមហាម៉ាស់, កំណើនយឺតនៃសេដ្ឋកិច្ចសកល, និង ការថមថយនៃតម្រូវការនៅតាមបណ្តាប្រទេសជាដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា ។ល។

ច្បាស់ណាស់ថា, ក្នុងបរិការណ៍នេះ, កម្ពុជាត្រូវសម្របជាប្រចាំ តាមនិន្នាការប្រែប្រួលសកល ដែលទាមទារនូវការយកចិត្តទុកដាក់ខ្ពស់ ចំពោះការលើកកម្ពស់ភាព-ជាអ្នកដឹកនាំ និង សមត្ថភាពស្ថាប័នគ្រប់កម្រិត ដោយផ្សារភ្ជាប់នឹងការធានាបាន នូវគោលនយោបាយសមស្រប និង សមត្ថភាពអនុវត្តជាក់ស្តែង, លទ្ធផលការងារ និង ការទទួលខុសត្រូវ ដើម្បីឆ្លើយតបនឹងអាទិភាពសំខាន់ៗ នៅក្នុងដំណាក់កាលថ្មី មានជាអាទិ៍៖ ការពង្រឹងអភិបាលកិច្ច; ការទ្រទ្រង់កំណើន និង ការធ្វើទំនើបកម្មសេដ្ឋកិច្ច; ការបង្កើតការងារ, ទាំងគុណភាព និង បរិមាណ; ការលើកស្ទួយវិស័យឯកជន និង សហគ្រិនភាព; ការកសាងមូលធនមនុស្ស ដោយផ្តោតជាពិសេស លើគុណភាពវិស័យអប់រំ, សេវាសុខាភិបាល និង សីលធម៌សង្គម; ការលើកស្ទួយសេវាគាំពារសង្គម និង សុខុមាលភាពប្រជាជន, ពិសេស សម្រាប់គ្រួសារងាយរងហានិភ័យ និង ក្រុមជនងាយរងគ្រោះ; ការពង្រឹងគុណភាពនគរូបនីយកម្ម, ជាពិសេស ការកាត់បន្ថយគម្លាតរវាងទីក្រុង និង ជនបទ; ការពង្រឹងចីរភាពបរិស្ថាន និង ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ; ព្រមទាំងការជំរុញធ្វើបរិវត្តកម្មឌីជីថល, ទាំងក្នុងសង្គម និង សេដ្ឋកិច្ច ។

នៅក្នុងក្របខណ្ឌនៃទស្សនវិស័យនេះ និង ផ្អែកតាម **កម្មវិធីនយោបាយ** របស់ខ្លួន, រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា, ក្រោមការដឹកនាំដ៏ស្វាហាប់ និង

ឈ្លាសវៃ របស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, ដែលជាអគ្គមគ្គុទ្ទេសក៍វ័យក្មេងដ៏ឆ្នើម និង ពោរពេញដោយសមត្ថភាព, ចំណេះដឹង និង ថាមពល, បានដាក់ចេញ នូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាល ទី ១** ដើម្បី **កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព, និង ចីរភាព**, ដោយផ្ដោតជាសំខាន់ លើរបៀបវារៈ ជានា «**ប្រសិទ្ធភាពសមិទ្ធកម្ម**» តាមរយៈការអនុវត្តអភិក្រម «**ឆ្លុះកញ្ចក់, ងូតទឹក, ដុសក្អែល, ព្យាបាល និង វះកាត់**» និង អភិក្រម «**ជវភាពនៃប្រព័ន្ធតួអង្គតែមួយ**» ។ ជាមួយនឹង**បាវចនា ៥** គឺ៖ **កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព និង ចីរភាព**, **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** បានកំណត់យក **អាទិភាពគន្លឹះ ៥** គឺ៖ «**មនុស្ស, ផ្លូវ, ទឹក, ភ្លើង**, និង **បច្ចេកវិទ្យា**, ជាពិសេស គឺ **បច្ចេកវិទ្យាឌីជីថល**» សម្រាប់ឆ្លើយតបទៅនឹងបដិវត្តឧស្សាហកម្មទី ៤.០ និង បរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ច និង សង្គមកម្ពុជា ក៏ដូចជាឆ្លើយតបនឹងតម្រូវការ ក្នុងការលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច ដែលជាគ្រឹះ និង ជាមធ្យោបាយដ៏សំខាន់នៃការសម្រេចបាននូវ **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០** សំដៅប្រែក្លាយកម្ពុជា ទៅជាប្រទេសមានចំណូលខ្ពស់ ។

ជាការពិត, ការលើកស្ទួយវិស័យកសិកម្ម និង ការអភិវឌ្ឍជនបទ នៅតែជាអាទិភាពចម្បងមួយ របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា ។ ជាក់ស្តែង, **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាល ទី ១** បានដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រនៃការបន្តពង្រឹងតួនាទី និង អភិវឌ្ឍវិស័យកសិកម្មកម្ពុជា ឱ្យកាន់តែមានលក្ខណៈទំនើប និង មានភាពធន់កាន់តែខ្ពស់ ព្រមទាំងការបន្តគាំទ្រដល់ការអភិវឌ្ឍជនបទ សំដៅជានាសន្តិសុខ និង សុវត្ថិភាពស្បៀង, បង្កើនតម្លៃបន្ថែមកាន់តែខ្ពស់, ជំរុញភាពប្រកួតប្រជែង និង លើកកម្ពស់គុណភាព និង កម្រិតជីវភាពរស់នៅ របស់ប្រជាពលរដ្ឋនៅជនបទ ក៏ដូចជា កាត់បន្ថយគម្លាត រវាងអ្នករស់នៅទីក្រុង និង អ្នករស់នៅជនបទ ។

## ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!

ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីនយោបាយ និង គោលនយោបាយ របស់រាជរដ្ឋាភិបាល, ធនាគារអភិវឌ្ឍន៍ជនបទ (RDB) ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៨ និង

ត្រូវបានធ្វើបរិវត្តកម្មទៅជាធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម (ARDB) នៅឆ្នាំ ២០១៩ ក្នុងគោលបំណងផ្តល់ហិរញ្ញប្បទាន ដល់វិស័យកសិកម្ម, ដែលជាវិស័យអាទិភាព របស់រាជរដ្ឋាភិបាល, សំដៅលើកស្ទួយកម្រិតជីវភាពរស់នៅ របស់ប្រជាពលរដ្ឋនៅជនបទ និង បំពេញចន្លោះខ្វះខាតនៃការផ្តល់ហិរញ្ញប្បទាន ក្នុងការអភិវឌ្ឍវិស័យកសិកម្ម និង សេដ្ឋកិច្ចជនបទ ។ លើសពីនេះ, ដោយមានការយកចិត្តទុកដាក់ និង ការគាំទ្រពីសំណាក់រាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ធនាគារជាតិនៃកម្ពុជា, ធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម សម្រេចបាននូវសមិទ្ធផលជាច្រើនជាបន្តបន្ទាប់ ដូចត្រូវបានគូសរំលេចក្នុងរបាយការណ៍ របស់ **ឯកឧត្តមបណ្ឌិត កៅ ថាច** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម, រួមបញ្ចូលនូវ ការកសាងនូវអគារការិយាល័យកណ្តាលថ្មី ដែលត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នាពេលនេះផងដែរ ។ អគារការិយាល័យកណ្តាលថ្មីនេះ គឺជាសក្ខីភាពជាក់ស្តែងនៃសមិទ្ធផល ប្រកបដោយមោទនភាព និង ជាសញ្ញានៃការបោះជំហានទៅមុខ ប្រកបដោយភាពស្វាហាប់ របស់ធនាគារធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម ក្នុងការបំពេញបេសកកម្មរបស់ខ្លួន នៅក្នុងដំណាក់កាលបន្តបន្ទាប់ខាងមុខ សំដៅពង្រីកវិសាលភាពប្រតិបត្តិការ, ពង្រឹងគុណភាព និង ផ្តល់ភាពកាន់តែងាយស្រួល ក្នុងការផ្តល់សេវាធនាគារ ក៏ដូចជា ដើម្បីបង្កើនការជឿទុកចិត្តពីសំណាក់អតិថិជន និង សាធារណជនទូទៅ ។

សម្រាប់ទិសដៅអនាគត, ធនាគារអភិវឌ្ឍជនបទ និង កសិកម្ម ចាំបាច់ត្រូវបន្តបេសកកម្ម និង តួនាទីរបស់ខ្លួន ឱ្យបានកាន់តែប្រសើរ ក្នុងនាមជាធនាគារគោលនយោបាយរបស់ជាតិ ក្នុងការផ្តល់ហិរញ្ញប្បទានដល់ការអភិវឌ្ឍជនបទ និង វិស័យកសិកម្ម, ការចូលរួមអភិវឌ្ឍខ្សែក្រវ៉ាត់កសិកម្ម និង ការផ្គត់ផ្គង់, ខ្សែច្រវាក់តម្លៃ និង ផលិតភាព, ក្នុងវិស័យកសិកម្ម និង សេដ្ឋកិច្ចជនបទ ឱ្យកាន់តែសកម្ម និង ខ្លាំងក្លាបន្ថែមទៀត ប្រកបដោយប្រសិទ្ធភាព និង ជវភាពខ្ពស់ ។

ក្នុងស្មារតីជំរុញប្រសិទ្ធភាពប្រតិបត្តិការ របស់ធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម ក្នុងការចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ដូចបានគូសរំលេចខាងលើ, ខ្ញុំសូមស្នើឱ្យក្រុមប្រឹក្សាភិបាល, ថ្នាក់ដឹកនាំ និង មន្ត្រី-បុគ្គលិកគ្រប់លំដាប់ថ្នាក់របស់ធនាគារ យកចិត្តទុកដាក់លើការងារសំខាន់មួយចំនួន ដូចខាងក្រោម ៖

**ទី១**-គិតគូរដាក់ចេញនូវវិធានការ និង ផែនការសកម្មភាពលម្អិត ស្របតាមដែន-សមត្ថកិច្ចរបស់ខ្លួន ដោយសហការជិតស្និទ្ធ ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តឱ្យសម្រេចបានលទ្ធផលល្អ នូវភារកិច្ចទាំងឡាយដែលរាជរដ្ឋាភិបាល ប្រគល់ជូន;

**ទី២**-បន្តចូលរួមក្នុងដំណើរការរៀបចំ, តាមដាន និង វាយតម្លៃការអនុវត្តគោលនយោបាយ និង យុទ្ធសាស្ត្រ របស់រាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងវិស័យកសិកម្ម និង ការអភិវឌ្ឍជនបទ ដើម្បីបើកកាលានុវត្តភាពបន្ថែម ក្នុងការបញ្ជ្រាបផលិតផល និង សកម្មភាពរបស់ធនាគារ ឱ្យកាន់តែច្រើន និង ទូលំទូលាយ;

**ទី៣**-ចូលរួមកៀរគរទុនវិនិយោគពីវិស័យឯកជន ឱ្យបានកាន់តែច្រើន ដើម្បីចាក់បញ្ចូលទៅក្នុងខ្សែច្រវាក់តម្លៃកសិកម្ម សំដៅរួមចំណែកអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ, ទាំងមុនពេល និង ក្រោយពេលប្រមូលផល; សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាទីផ្សារសម្រាប់កសិករ; ចូលរួមបង្កើនការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ឱ្យបានកាន់តែទូលំទូលាយ; ព្រមទាំងចូលរួមជួយជំរុញការកែច្នៃ និង ការនាំចេញនូវផលិតផលកសិកម្ម និង កសិ-ឧស្សាហកម្ម;

**ទី៤**-បន្តចូលរួមលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និង ជំរុញការពង្រីកសេវាធនាគារតាមបែបឌីជីថល ស្របតាមគោលនយោបាយអភិវឌ្ឍន៍ធុរកិច្ចឌីជីថល តាមរយៈការវិនិយោគបន្ថែម លើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង ការបង្កើតផលិតផលថ្មី;

**ទី៥**-បន្តជំរុញការធ្វើពិពិធកម្មនៃការផ្តល់ឥណទាន, ដោយបែងចែកតាមតំបន់ និង វិស័យអាទិភាព, តាមរយៈការបង្កើនការផ្សព្វផ្សាយ ឱ្យកាន់តែទូលំទូលាយ និង ការបង្វិតសេវា ឱ្យកាន់តែកៀកនឹងអតិថិជន;

**ទី៦**-ជំរុញការផ្តល់ហិរញ្ញប្បទានបៃតង (Green Financing) ដើម្បីជានាការ-អភិវឌ្ឍ ប្រកបដោយនិរន្តរភាព តាមរយៈការរៀបចំផ្តល់ការអនុគ្រោះបន្ថែម ឬ ផ្តល់លក្ខខណ្ឌពិសេស ជាដើម;

**ទី៧**-ចូលរួមលើកកម្ពស់ការអភិវឌ្ឍកសិករ ដែលផលិតសម្រាប់ផ្គត់ផ្គង់គ្រួសារទៅជាកសិករសហគ្រិន តាមរយៈការផ្តល់ឥណទានសម្រាប់ពង្រីក និង លើកកម្ពស់ផលិតកម្មកសិកម្ម; និង

**ទី៨**-បន្តលើកកម្ពស់ប្រសិទ្ធភាពនៃប្រតិបត្តិការរបស់ធនាគារ តាមរយៈការ-ពង្រឹងសមត្ថភាពមន្ត្រី-បុគ្គលិក, ការបណ្តុះបណ្តាលជំនាញបន្ថែម ព្រមទាំងការរៀបចំ

ប្រព័ន្ធផ្តល់ការលើកទឹកចិត្តសមស្រប សម្រាប់មន្ត្រី-បុគ្គលិកគ្រប់លំដាប់ថ្នាក់ ដោយគួបផ្សំជាមួយនឹងការពង្រឹងវិន័យការងារផងដែរ ។

**ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!**

ជាថ្មីម្តងទៀត, ខ្ញុំមានជំនឿយ៉ាងមុតមាំថា អគារការិយាល័យកណ្តាលថ្មីនេះ នឹងរួមចំណែកក្នុងការបង្កើនប្រសិទ្ធភាព និង គុណភាពនៃការផ្តល់សេវាជូនអតិថិជន របស់ធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម ឱ្យបានកាន់តែប្រសើរឡើងបន្ថែមទៀត ។ ខ្ញុំក៏សូមស្នើឱ្យថ្នាក់ដឹកនាំ, មន្ត្រី និង បុគ្គលិកទាំងអស់ យកចិត្តទុកដាក់ខ្ពស់ ក្នុងការថែទាំអគារថ្មីនេះ ឱ្យបានល្អ និង ស្អាត សម្រាប់ការប្រើប្រាស់យូរអង្វែងទៅអនាគត ។

នៅចុងបញ្ចប់, ខ្ញុំសូមជូនពរដល់ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ជាពិសេស ថ្នាក់ដឹកនាំ និង មន្ត្រី-បុគ្គលិកគ្រប់ជាន់ថ្នាក់នៃធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម បានប្រកបដោយសុខភាពល្អបរិបូរណ៌, សម្រេចបានជោគជ័យធំធេងបន្ថែមទៀត ក្នុងការបំពេញបេសកកម្មបម្រើជាតិ និង មាតុភូមិ, ព្រមទាំងទទួលបាននូវវិបុលភាព និង សុភមង្គល ក្នុងក្រុមគ្រួសាររៀងៗខ្លួន នៅក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាព ។

ខ្ញុំសូមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នូវ **អគារការិយាល័យកណ្តាលថ្មី** របស់ធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម ចាប់ពីពេលនេះតទៅ ៕

**សូមអរគុណ!**